# ដំណាំសណ្តែកគួរ



## ការរៀបចំដី

- រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ ស.ម យ៉ាងតិចនៅរដូវវស្សា)
- ពង្រាយជីលាមកគោស្ងួតរឺជីកំប៉ុស្ត៍ និងជីកែងៗពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយ ចំបើងអោយបានកំរាស់យ៉ាងតិច៥សង់ទីម៉ែត្រ រឺប្រើគំរបជីផ្លាស់ស្ទិក ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី



## ការដាំដោយគ្រាប់ផ្ទាល់

- ដាក់២គ្រាប់ក្នុង១រណ្តៅដែលមានជំរៅ២ស.ម បើកប់គ្រាប់ជ្រៅពេកគ្រាប់សណ្តែកពិបាកដុះពន្លកចេញពីដី ។បន្ទាប់ពីដាក់គ្រាប់ហើយត្រូវស្រោចទឹកអោយបានគ្រប់គ្រាន់។ បើទឹកតិចពេក គ្រាប់មិនអាចដុះឬច្រើនពេក ធ្វើអោយគ្រាប់អាចរលួយ ។
- ត្រូវស្រោចទឹកកូនសណ្តែកឲ្យបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយជាពិសេសរវាងពី ២-៣ អាទិត្យបន្ទាប់ពីកូនដុះហើយ



## ការថែទាំ

- ត្រូវដាក់ទ្រើងភ្លាមបន្ទាប់ពីដាំគ្រាប់ហើយ មិនត្រូវអោយយឺតជាង៧ថ្ងៃទេ បើដាក់ទ្រើងយឺតធ្វើអោយសណ្តែកមិនល្អ



- កុំធ្វើទ្រើងខ្ពស់ពេក នាំអោយគ្រោះថ្នាក់ពេលបាញ់ថ្នាំពុល
- ត្រូវស្រោចទឹកអោយបានគ្រប់គ្រាន់នៅពេលព្រឹក ជៀសវាងស្រោចទឹកច្រើនពេកធ្វើឲ្យដីសើមជ្រុលនៅពេលថ្ងៃល្ងាចវាអាចបង្កអោយមានបញ្ហាដល់ដំណាំបានធ្វើស្មៅឲ្យបានញឹកញាប់តែជៀសវាងធ្វើស្មៅពេញដីនៅសើមជោគជាំ ។



ការប្រើប្រាស់ជី ( បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន )

| ពេលវេលា | ប្រភេទជីប្រើក្នុងចន្លោះគុម្ពទាំងបួន | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| មុនដាំគ្រាប់ | ជីលាមកសត្វស្ងួត ០.៥ គីឡូក្រាម ជី អិន ប៉េ កា (១៥. ១៥.១៥)កន្លះស្លាបព្រាបាយ (៥ក្រាម) | ពង្រាយលើរងហើយកាប់ច្របល់និងដី |
| ៣ អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជីអ៊ុយរ៉េ  កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់កន្លះតឹក |
| ៥ អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជី អិន ប៉េ កា (១៥. ១៥.១៥)កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| | ចាប់ផ្តើមប្រមូលផល | |
| ៧ អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជី អិន ប៉េ កា (១៥. ១៥.១៥)កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ១០អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជី អិន ប៉េ កា (១៥. ១៥.១៥) កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីរាក់ៗ ចំងាយពីគល់១តឹកកន្លះ |
| ១៤ អាទិត្យបន្ទាប់ពីដាំ | បញ្ចប់ការប្រមូលផល | |

## ការការពារសត្វល្អិត និងការកំចាត់

- កុំដាំសណ្តែកនៅលើដីដដែលៗនាំអោយកើតមានសត្វល្អិតនិងជំងឺច្រើន ពិបាកកំចាត់វា
- ត្រូវព្យាយាមកំចាត់ដោយដៃនៅពេលសត្វល្អិតមានចំនួនតិចទើបបាញ់ថ្នាំពុលមានប្រសិទ្ធិភាព
- បេះក្ងួរសណ្តែកដែលមានដង្កូវស៊ីចេញ ហើយយកវាទៅដុត កប់ រឺអោយសត្វស៊ី។ បើទុកក្ងួរសណ្តែកមានដង្កូវនៅ ក្នុងចំការសណ្តែក ដង្កូវនៅដែលនៅក្នុងផ្លែនោះ ក្លាយជាមេអំបៅហើយពងដាក់សណ្តែកកាន់តែច្រើនជាងមុន។







## ប្រការចងចាំ

- កុំប្រើថ្នាំកំចាត់សត្វល្អិតនិងជំងឺឈ្មោះដដែលៗ វាធ្វើអោយសត្វល្អិតនិងជំងឺធន់ទ្រាំជាមួយថ្នាំ ពិបាកកំចាត់នៅពេលក្រោយ។
- កុំប្រើថ្នាំពុលលាយចូលគ្នានៅពេលបាញ់ វាធ្វើអោយថ្នាំគ្មានប្រសិទ្ធិភាព ហើយសត្វល្អិត ដង្កូវរហ័សសាំនិងថ្នាំ ពិបាកកំចាត់ វាពេលក្រោយ។ ជាពិសេសកុំប្រើថ្នាំមានវណ្ណពណ៌ក្រហម( សញ្ញាក្បាលខ្មោច )វាគ្រោះថ្នាក់ ដល់សុខភាពខ្លាំងណាស់។
- ដកដើមសណ្តែកគួរចេញភ្លាមបន្ទាប់ពីបញ្ចប់ប្រមូលផលហើយ។ កុំទុកដើមដែលឈប់ប្រមូលផលហើយនៅនឹងក្នុងចំការ។ ពីព្រោះវាជាជំរកសត្វល្អិតនិងជំងឺបំផ្លាញទៅដំណាំផ្សេងទៀតបាន។
- ត្រូវប្តូរមកដាំដំណាំផ្សេងដូចជាត្រប់ ពោត ប៉េងប៉ោះវិញ មុនដាំសណ្តែកបន្ត



## ការប្រមូលផល

កាត់ផ្លែសណ្តែកនៅពេលព្រឹក និងមិនត្រូវទុកផ្លែដែលកាត់ហើយអោយត្រូវថ្ងៃក្តៅទេ ៕








### ឯកសារពិគ្រោះ

- សៀវភៅណែនាំអំពីបច្ចេកទេសដំណាំបន្លែ, ២០១១
- សៀវភៅណែនាំបច្ចេកទេសកសិករ ផលិតកម្មដំណាំបន្លែ, ២០១៣




ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ដំណាំសណ្តែកគួរ




សហការផលិតដោយ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងកម្មវិធី
អភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់-ត្រជាក់បៃតង ខេត្តសៀមរាប
២០១៣



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧